ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

## សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០០៩ និងទិសដៅការងារឆ្នាំ២០១០
## របស់ធនាគារជាតិនៃកម្ពុជា

នៅធនាគារជាតិនៃកម្ពុជា នាថ្ងៃទី១៨-១៩ ខែមករា ឆ្នាំ២០១០

សូមគោរព :

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកជួបជាមួយ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាមន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា ក្នុងឱកាសដែលយើងកំពុងប្រារព្ធធ្វើសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០០៩ និងទិសដៅការងារឆ្នាំ២០១០ របស់ធនាគារជាតិនៃកម្ពុជា បន្ទាប់ពីប្រជាជនកម្ពុជានៅទូទាំងប្រទេស បានប្រារព្ធខួបអនុស្សាវរីយ៍លើកទី៣១ នៃថ្ងៃមហាជ័យជំនះ ៧ មករា ឆ្នាំ១៩៧៩ លើរបបប្រល័យពូជសាសន៍ប៉ុល ពត និងខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ ។ ជារៀងរាល់ឆ្នាំ សន្និបាតបូកសរុបលទ្ធផលការងារ តែងរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយ និងអបអរសាទរពីលទ្ធផលការងារ ដែលធនាគារជាតិនៃកម្ពុជាបានសម្រេចកន្លងមក និងម្យ៉ាងទៀត ដើម្បីបង្កបរិយាកាសឱ្យមន្ត្រីបុគ្គលិករបស់យើង ទាំងនៅទីស្នាក់ការកណ្តាល និងនៅរាជធានី-ខេត្ត បានជួបប្រាស្រ័យ និងរាប់អានគ្នាកាន់តែជិតស្និទ្ធ ដូចយើងរស់នៅក្រោមដំបូលគ្រួសារតែមួយ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលជាតំណាងនាយកដ្ឋាននានានៅទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតរបស់យើងនាពេលនេះ ។

ខ្ញុំនៅចាំបានថា តាមរយៈសុន្ទរកថារបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងក្នុងឱកាសប្រារព្ធខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ (១៩៧៩-២០០៩) បានបង្ហាញឱ្យឃើញថា វិស័យធនាគារសម្រេចបាននូវស្នាដៃ និងសមិទ្ធផលជាច្រើន ក្នុងរយៈពេល ៣០ឆ្នាំកន្លងមកនេះ ហើយបានទទួលការគាំទ្រនិងអបអរសាទរយ៉ាងខ្លាំងពីសាធារណជនទូទៅ ហើយត្រូវបានគេចាត់ទុកថា វិស័យនេះពិតជាបានដើរតួនាទីស្នូលក្នុងការរួមចំណែកអភិវឌ្ឍ

សេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរយ៉ាងខ្លាំង ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ដែលបានរួមសាមគ្គីគ្នាជាប្រពៃណី ដើម្បីកសាងសមិទ្ធផលជូនធនាគារជាតិនៃកម្ពុជាកន្លងមក ពោលគឺបានរួមចំណែកកសាងប្រព័ន្ធធនាគារ យើងឱ្យមានសុវត្ថិភាព ទទួលបានការជឿទុកចិត្តពីសាធារណជនទូទៅ និងមានសុខភាពរឹងមាំ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

គោលបំណងសំខាន់នៃការរៀបចំអង្គសន្និបាតរបស់យើងថ្ងៃនេះ គឺដើម្បីផ្សព្វផ្សាយពី :

១- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០០៩

២- លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបានក្នុងឆ្នាំ២០០៩ កន្លងមក ។

## I/- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០០៩

ខ្ញុំសូមជម្រាបថា នៅក្នុងឆ្នាំ២០០៩ កន្លងមក ពិភពលោកយើងប្រឈមមុខនឹងបញ្ហាធំៗមួយចំនួន ដូចជា *១)*-ឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចជុំទី២ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុសកល *២)*-បាតុភូតជំងឺគ្រុនផ្តាសាយជ្រូក (AH1N1) និង *៣)*-គ្រោះធម្មជាតិមួយចំនួនកើតមាននៅក្នុងតំបន់ ។ កត្តាទាំងនេះហើយដែលធ្វើឱ្យកំណើនសេដ្ឋកិច្ចពិភពលោក និងប្រទេសនានានៅតាមតំបន់អឺរ៉ុប អាមេរិក អាហ្វ្រិក និងតំបន់អាស៊ីបានធ្លាក់ចុះយ៉ាងគំហុក ។ តាមការព្យាករណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅក្នុងឆ្នាំ២០០៩ សេដ្ឋកិច្ចពិភពលោកសង្ឃឹមថានឹងថយចុះក្នុងកម្រិត -១,១% ធៀបកាលពីដើមឆ្នាំត្រឹម -១,៣% ។ អត្រាកំណើនសេដ្ឋកិច្ចអាមេរិកនឹងថយចុះក្នុងកម្រិត -២,៧% សហគមន៍អឺរ៉ុប-៤,២% ប្រទេសជប៉ុន-៥,៤% ប្រទេសចិនកើន ៨% និងប្រទេសឥណ្ឌាកើន ៥,៤% ក្រុមប្រទេសអាស៊ានទាំង៥ នឹងកើនក្នុងកម្រិត ០,៧% និងនៅឆ្នាំ២០១០ នឹងកើនដល់៤% ។

បច្ចុប្បន្ននេះ ស្ថានភាពសេដ្ឋកិច្ចពិភពលោកហាក់ដូចជាមានភាពល្អប្រសើរឡើងវិញ បន្ទាប់ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិបានកំណែទម្រង់ការគ្រប់គ្រងរបស់ខ្លួន និងការបន្ថែមកញ្ចប់ថវិកាគាំទ្ររបស់រដ្ឋាភិបាល ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការដាក់ចេញនូវវិធានការពង្រឹងអភិបាលកិច្ចល្អ ក៏ដូចជាបទប្បញ្ញត្តិប្រុងប្រយ័ត្នផ្សេងៗសំដៅពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ គួបផ្សំនឹងគោលនយោបាយទ្រទ្រង់មួយចំនួន ដើម្បីជំរុញកំណើនសេដ្ឋកិច្ចរួចមក ។ ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយទាំងនេះ បានឈានទៅបញ្ចប់ទស្សនៈខ្វែងគ្នារវាងអ្នកនយោបាយ សេដ្ឋវិទូ អ្នកកំណត់គោលនយោបាយ និងអ្នកសិក្សាស្រាវជ្រាវនានា ចំពោះការស្វែងរកដំណោះស្រាយក្នុងការជ្រើសរើសគោលនយោបាយទ្រទ្រង់ស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ និងការអភិវឌ្ឍសេដ្ឋកិច្ច ។

ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ វិបត្តិសេដ្ឋកិច្ចពិភពលោក បានជះឥទ្ធិពលដល់វិស័យពិតនៃសេដ្ឋកិច្ច (Real sector) ដូចជា វិស័យនាំចេញផលិតផលវាយនភ័ណ្ឌ វិស័យទេសចរណ៍ វិស័យសំណង់ និងវិនិយោគផ្ទាល់ពី

បរទេស ខណៈដែលវិស័យកសិកម្មនៅមានកម្រិតរឹងមាំនៅឡើយ ។ នៅឆ្នាំ២០០៩ បើតាមការព្យាករណ៍ដោយប្រុងប្រយ័ត្នបែបសុទិដ្ឋិនិយមរបស់រាជរដ្ឋាភិបាល អត្រាកំណើននឹងមានកម្រិត ២.១% បើប្រៀបធៀបនឹង ៦.៨% នៅឆ្នាំ២០០៨ ។ ប៉ុន្តែ តាមការវាយតម្លៃបែបទុទិដ្ឋិនិយមរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបង្ហាញថា អត្រាកំណើនសេដ្ឋកិច្ចកម្ពុជានឹងមានកម្រិត -២.៧% ធនាគារពិភពលោក -២.៥% និងធនាគារអភិវឌ្ឍន៍អាស៊ី -១.៥% ។

## II/- លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបានក្នុងឆ្នាំ២០០៩ កន្លងមក

នៅឆ្នាំ២០០៩ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជាបានខិតខំបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃ តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន សំដៅរួមចំណែកពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ។

### លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

នៅឆ្នាំ២០០៩ ធនាគារជាតិនៃកម្ពុជា បានរួមចំណែកពង្រឹងស្ថានភាពម៉ាក្រូសេដ្ឋកិច្ចបានល្អប្រសើរ ទោះបីជាអត្រាកំណើនមានការថយចុះបន្តិច អត្រាអតិផរណាកើនឡើងបន្តិចក៏ដោយ ក៏តម្លៃប្រាក់រៀលមានស្ថិរភាពល្អប្រសើរដោយអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកចុះថ្លៃប្រមាណ ២.៣% ក្នុងឆ្នាំ២០០៩ ធៀបនឹងគ្រាដូចគ្នាឆ្នាំ២០០៨ ។ ស្ថិរភាពនៃតម្លៃប្រាក់រៀលបានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនទូទៅចំពោះសេដ្ឋកិច្ចកម្ពុជា ។ ចំណែកឯការគ្រប់គ្រងទុនបម្រុងអន្តរជាតិ យើងបានអនុវត្តដោយឈរលើមូលដ្ឋានប្រុងប្រយ័ត្ន គឺសុវត្ថិភាព និងសាច់ប្រាក់ងាយស្រួលជាចម្បង ។ នៅឆ្នាំ២០០៩ ទុនបម្រុងអន្តរជាតិវិនិយោគរបស់យើងបានកើនឡើងជាង ២.៦០០លានដុល្លារ ធៀបនឹងឆ្នាំ២០០៨ គឺកើន២៥.២% ដែលអាចធានា ការនាំចូលបាន ៤ខែ ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ហើយទទួលបានលទ្ធផលល្អប្រសើរ ដូចខាងក្រោម :

១). **វិស័យធនាគារ** មានការរីកចម្រើនទាំងវិសាលភាពនិងទំហំប្រតិបត្តិការ ហើយបានដើរតួនាទីស្នូលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ នៅក្នុងឆ្នាំ២០០៩ ផ្នែកវិសាលភាព យើងមានធនាគារពាណិជ្ជចំនួន ២៧ ធនាគារឯកទេសចំនួន ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណចំនួន ២០ ។ នៅឆ្នាំ២០០៩ មានធនាគារពាណិជ្ជចំនួន ៣ មកពីប្រទេសវៀតណាម និងឥណ្ឌា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយបានបើកដំណើរការអាជីវកម្មនៅកម្ពុជា ។ ការបន្តចូលមកវិនិយោគនេះ បានបង្ហាញយ៉ាងច្បាស់ពីកំណើនជំនឿទុកចិត្តរបស់វិនិយោគិនបរទេស មកលើប្រព័ន្ធធនាគារនៅកម្ពុជា ជាពិសេស មានជំនឿទុកចិត្តចំពោះនយោបាយរបស់រាជរដ្ឋាភិបាល ។

ចំណែកឯទំហំប្រតិបត្តិការវិញ ទ្រព្យសកម្មសរុបរបស់ប្រព័ន្ធធនាគារបានកើនឡើង ២០.៥២% និងប្រាក់បញ្ញើសរុបក្នុងប្រព័ន្ធធនាគារកើនឡើង ៣២.៦៧% អ្នកដាក់ប្រាក់បញ្ញើសរុបកើនឡើង ៣៨.៣៦% និងឥណទានចំពោះ

វិស័យឯកជនបានកើនឡើង ៣.១៨% បើប្រៀបធៀបនឹងខែធ្នូ ឆ្នាំ២០០៨ ។ ការវិវត្តរីកចម្រើននេះ គួបផ្សំនឹងការអនុវត្តវិធានការប្រុងប្រយ័ត្នយ៉ាងហ្មត់ចត់ បានធ្វើឱ្យឥណទានមិនដំណើរការ (NPL) ថយចុះជាលំដាប់រហូតមកក្រោម ៦% នៃកញ្ចប់ឥណទានសរុបនៅខែធ្នូ ឆ្នាំ២០០៩ ។

**២).ការងារត្រួតពិនិត្យធនាគារ** ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ និងបានសហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (CAFIU) យើងបានពង្រឹងការគ្រប់គ្រងប្រព័ន្ធធនាគារជាប់ជាប្រចាំ តាមរយៈការចុះទៅត្រួតពិនិត្យដល់ទីកន្លែង និងត្រួតពិនិត្យលើឯកសារ ដើម្បីជួយគ្រឹះស្ថានធនាគារទាំងនោះឱ្យពង្រឹងការគ្រប់គ្រង និងការងារសវនកម្មផ្ទៃក្នុងរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង ព្រមទាំងឱ្យគ្រឹះស្ថានធនាគារទាំងនេះធ្វើការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាសាធារណៈ ដើម្បីបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ។

នៅឆ្នាំ២០០៩ ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវបានពង្រឹង សម្ពាធអតិផរណាថយចុះ និងធនាគារនីមួយៗចេះគ្រប់គ្រងហានិភ័យដោយខ្លួនឯង យើងបន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ចពី ១៦% មក ១២% និងលុបចោលពិដានឥណទាន ១៥% វិញ ដើម្បីជំរុញការផ្តល់ឥណទានបន្ថែមទៅដល់វិស័យសេដ្ឋកិច្ច និងរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ។

**៣).វិស័យមីក្រូហិរញ្ញវត្ថុ** មានការរីកចម្រើនយ៉ាងឆាប់រហ័ស និងមានហេដ្ឋារចនាសម្ព័ន្ធរឹងមាំដល់ជនបទ ហើយត្រូវបានទទួលស្គាល់ពីមជ្ឈដ្ឋានក្នុងនិងក្រៅប្រទេសថា **ជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា** ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ហើយប្រជាពលរដ្ឋកម្ពុជានៅតែមានការយល់ដឹងកាន់តែប្រសើរឡើងពីសារៈសំខាន់នៃសេវាមីក្រូហិរញ្ញវត្ថុ និងវប្បធម៌ឥណទាន។

**៤).ការពង្រឹងក្របខ័ណ្ឌច្បាប់** ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ត្រូវប្រកាសឱ្យប្រើនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩ សម្រាប់ធ្វើជាមូលដ្ឋានគតិយុត្តិ សម្រាប់កៀងគរប្រភពទុនរយៈពេលវែងទៅអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម (SME) នៅកម្ពុជា។ ក្រៅពីនេះ យើងបានរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ហើយបានបញ្ជូនសេចក្តីព្រាងនេះទៅទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ ។ យើងបានបន្តការកែលម្អវិធានការប្រុងប្រយ័ត្ន បានធ្វើចំណាត់ថ្នាក់ឥណទានតាមវិស័យ និងតាមកម្រិតហានិភ័យ ដើម្បីពង្រឹងប្រព័ន្ធធនាគារឱ្យប្រព្រឹត្តទៅដោយរលូន មានសុខភាពល្អ និងប្រសិទ្ធភាព ។

**៥).អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ** ត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីរួមចំណែកជាមួយសហគមន៍ជាតិ-អន្តរជាតិ ការពារទប់ស្កាត់ និងប្រឆាំងរាល់បទល្មើសទាក់ទងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។ ដើម្បីអនុវត្តច្បាប់នេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានសហការជាមួយនាយកដ្ឋានត្រួតពិនិត្យ ទាំងអាជ្ញាធរពាក់ព័ន្ធ បានចុះទៅត្រួតពិនិត្យយន្តការអនុវត្តច្បាប់ ដើម្បីពិនិត្យមើលប្រតិបត្តិការសង្ស័យ និងរបាយការណ៍លំហូរសាច់ប្រាក់សង្ស័យរបស់គ្រឹះស្ថានធនាគារ ។

កាលពីចុងឆ្នាំ២០០៩ អង្គភាពនេះបានសហការជាមួយអគ្គលេខាធិការដ្ឋាន APG រៀបចំសិក្ខាសាលាគំរូ នៅខេត្តសៀមរាប ដោយមានការចូលរួមពីប្រទេសជាសមាជិកទាំងអស់ សរុបអ្នកចូលរួមប្រមាណ ២០០នាក់ ។

៦)_**ការពង្រឹងអភិបាលកិច្ច** ធនាគារជាតិនៃកម្ពុជាបានពង្រឹងការងារសវនកម្មផ្ទៃក្នុង និងការងារអធិការកិច្ចឱ្យកាន់តែស៊ីជម្រៅថែមទៀត តាមរយៈការចេញប្រកាសមួយចំនួនពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុង ។ នៅឆ្នាំ២០០៩ មន្ត្រីជំនាញយើងបានចុះធ្វើសវនកម្មនៅទីស្នាក់ការកណ្តាល និងនៅសាខារាជធានី-ខេត្ត ។ យើងក៏បានបញ្ជូនមន្ត្រីជំនាញទៅហាត់រៀនពីការងារសវនកម្ម នៅធនាគារកណ្តាលលុចហ្សំបួរ ធនាគារកណ្តាលអាល្លឺម៉ង់ និងនៅប្រទេសអាមេរិចផងដែរ ។ ចំពោះការងារអធិការកិច្ច យើងបានចុះឆ្មក់ត្រួតពិនិត្យដោយមិនជូនដំណឹងមុន ចំនួន ៩លើក ទៅលើការងារគ្រប់គ្រងសុវត្ថិភាពសាច់ប្រាក់ និងលំហូរការងារជាប់ជាប្រចាំនៅទីស្នាក់ការកណ្តាល និងសាខារាជធានី-ខេត្ត។

៧)_**ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជារាជធានី_ខេត្ត** គឺជាការងារអាទិភាពរបស់យើង ដែលចាំបាច់ត្រូវពង្រឹងប្រតិបត្តិការរបស់ខ្លួនទាំងនៅទីស្នាក់ការកណ្តាល និងសាខាខេត្ត ដើម្បីចូលរួមអនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី ២ ។ យើងបានរៀបចំកែលម្អការិយាល័យធ្វើការនៅសាខាធនាគារជាតិនៃកម្ពុជាតាមខេត្តមួយចំនួន ដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងគណនីរដ្ឋ និងធ្វើឱ្យកាន់តែរលូន ចំពោះការបើកប្រាក់បៀវត្សជូនអង្គភាពរដ្ឋជុំវិញខេត្ត និងទទួលបានការបង់ពន្ធគ្រប់ប្រភេទ។

យើងបានធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា គឺប្រព័ន្ធធនាគារស្នូល (CBS) ក្នុងគោលបំណងដើម្បី *១)*-ពង្រឹងតម្លាភាពនិងជួយសម្រួលប្រតិបត្តិការគ្រប់គ្រងលំហូរការងាររវាងនាយកដ្ឋានអាទិភាព ៤ គឺ នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងនាយកដ្ឋានគណនេយ្យ *២)*-ពន្លឿនប្រតិបត្តិការបើក-ដាក់ប្រាក់ ការបង់ពន្ធ និងការផ្ទេររវាងគណនី និង *៣)*-ដើម្បីឱ្យនាយកដ្ឋានទាំង ៤ ទទួលបានទិន្នន័យក្នុងពេលដំណាលគ្នា (Real time) ចំពោះប្រតិបត្តិការនីមួយៗ ។ បន្ទាប់ពីបញ្ចប់ការតំឡើងប្រព័ន្ធធនាគារស្នូល និងការបណ្តុះបណ្តាលមន្ត្រីជំនាញនៃនាយកដ្ឋានជំនាញទាំង៤ រួចមកយើងនឹងដាក់ឱ្យសាកល្បងអនុវត្តនៅខែកុម្ភៈ ឆ្នាំ២០១០ ខាងមុខនេះ ។

៨)_**ការអភិវឌ្ឍទីផ្សារអន្តរធនាគារ** នៅឆ្នាំ២០០៩ កន្លងមក ដើម្បីអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារ និងទីផ្សារមូលបត្រនៅកម្ពុជា ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឯកភាពគ្នាចេញប្រកាសរួមក្នុងជំហានដំបូងថា នឹងបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុអាចជួញដូរបានរយៈពេលខ្លី ដើម្បីជំរុញដំណើរការបង្កើត ទីផ្សារអន្តរធនាគារ និងទីផ្សារមូលបត្រនៅកម្ពុជា ។

ធនាគារជាតិនៃកម្ពុជា បានរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិច្បាប់មួយចំនួនរួចហើយ ដើម្បីធ្វើមូលបត្រនីយកម្មប្រាក់បញ្ញើមានកាលកំណត់របស់បណ្តាធនាគារនៅធនាគារជាតិនៃកម្ពុជា ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិចារណាអំពីការបោះផ្សាយឧបករណ៍ឥណទានរយៈពេលខ្លីដែលអាចជួញដូរបាន ក្នុងពេលសមស្របខាងមុខនេះស្របតាមនីតិវិធីច្បាប់ជាធរមាន ដើម្បីអភិវឌ្ឍទីផ្សារអន្តរធនាគារ និងទីផ្សារមូលបត្រនៅកម្ពុជា ។

៩)-**ការឈប់គ្រប់គ្រងអាជីវកម្មលក់ដូរគ្រឿងអលង្ការធ្វើពីលោហធាតុ និងត្បូងថ្មមានតម្លៃ** ពីមុនយើងធ្វើការគ្រប់គ្រងលើអាជីវកម្មលក់ដូរគ្រឿងអលង្ការ ដោយផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ប៉ុន្តែចាប់ពីខែមិថុនា ឆ្នាំ២០០៩ មក យើងបានឈប់ផ្តល់លិខិតអនុញ្ញាតសម្រាប់ការធ្វើអាជីវកម្មគ្រឿងអលង្ការទៀតហើយព្រោះគ្រឿងអលង្ការមិនត្រូវបានចាត់ទុកជារូបិយប័ណ្ណទេ ។ យើងសម្រេចផ្ទេរប្រភេទអាជីវកម្មគ្រឿងអលង្ការឱ្យស្ថិតក្រោមសមត្ថកិច្ចក្រសួងពាណិជ្ជកម្មគ្រប់គ្រង ហើយយើងគ្រប់គ្រងតែសកម្មភាពធ្វើអាជីវកម្មលោហធាតុ និងត្បូងថ្មមានតម្លៃ ដែលចាត់ទុកជារូបិយប័ណ្ណប៉ុណ្ណោះ ។

១០)-**សមាគមមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា** រយៈពេលកន្លងមក បានបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្ម និងបានជួយរួមចំណែកដោះស្រាយការលំបាករបស់មន្ត្រីបុគ្គលិករបស់យើងបានមួយចំនួន និងបានទទួលការគាំទ្រយ៉ាងខ្លាំងពីមន្ត្រីបុគ្គលិករបស់យើងផងដែរ ។ ដើម្បីឱ្យសមាគមយើងមានដំណើរការកាន់តែមានប្រសិទ្ធភាពថែមទៀត ចាំបាច់ត្រូវបង្កើតកម្មវិធីប្រជុំជីវភាពនៅតាមបណ្តានាយកដ្ឋាននិងអង្គភាពនីមួយៗ ដើម្បីទទួលបាននូវរបាយការណ៍ជាក់ស្តែង ស្តីពីការលំបាករបស់មន្ត្រីបុគ្គលិកដោយផ្ទាល់ ។ ជាក់ស្តែង ទំហំនៃការលំបាករបស់មន្ត្រីបុគ្គលិកយើងមានលក្ខណៈខុសគ្នាពីម្នាក់ទៅម្នាក់ ពីមួយករណីទៅមួយករណី ដូច្នេះ សូមឱ្យសមាគមរបស់យើងធ្វើការពិចារណាលើទំហំនៃការខូចខាត ឬផលប៉ះពាល់បន្ថែមពីលើគោលការណ៍បច្ចុប្បន្នរបស់យើង ជាពិសេស ការឧបត្ថម្ភផ្នែកសុខភាព ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

១១)-ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិវិញ នៅឆ្នាំ២០០៩ ធនាគារជាតិនៃកម្ពុជាមានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិផ្សេងៗ ដូចជា :

**មូលនិធិរូបិយវត្ថុអន្តរជាតិ** (IMF) កាលពីត្រីមាសទី១ ឆ្នាំ២០០៩ ក្រុមបេសកកម្ម IMF បានមកបំពេញបេសកកម្មមួយលើក និងបានកោតសរសើរធនាគារជាតិនៃកម្ពុជា ក្នុងការចាត់វិធានការទាន់ពេលក្នុងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល ការបង្កើតឧបករណ៍ឥណទានវិបារូបនី (OD) ការពង្រឹងប្រព័ន្ធចំណាត់ថ្នាក់ឥណទាន និងប្រព័ន្ធទុនបម្រុងកាតព្វកិច្ចបានល្អប្រសើរ ។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបន្តផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា ដើម្បីពង្រឹងប្រសិទ្ធភាពការត្រួតពិនិត្យធនាគារថែមទៀត ។

**ធនាគារពិភពលោក** (WB) ក្រុមបេសកកម្មធនាគារពិភពលោកផ្នែករតនាគារ បានមកបំពេញបេសកកម្មនៅធនាគារជាតិនៃកម្ពុជា ដើម្បីបណ្តុះបណ្តាលមន្ត្រីជំនាញរបស់នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ ដើម្បីពង្រឹងឯកទេសកម្មផ្នែកវិនិយោគលើទុនបម្រុងអន្តរជាតិ ។

**ធនាគារអភិវឌ្ឍន៍អាស៊ី** (ADB) ធនាគារជាតិនៃកម្ពុជា សហការជាមួយបណ្តាក្រសួងពាក់ព័ន្ធបានដើរតួនាទីស្នូលក្នុងការអនុវត្តគម្រោងការងារនៅក្នុងអនុកម្មវិធីទី៣ ដោយរលូន ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ២០០៦-២០១៥ ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយបច្ចេកទេស ដើម្បីរៀបចំធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់នាយកដ្ឋានស្នូលចំនួន ៤ និងរៀបចំប្រព័ន្ធទូទាត់ជាតិបន្ថែមទៀត ។

**ក្រុមប្រទេសអាស៊ាន** (ASEAN) នៅឆ្នាំ២០០៩ ប្រតិភូធនាគារជាតិនៃកម្ពុជា បានចូលរួមជាប្រចាំក្នុងកិច្ចប្រជុំថ្នាក់នយោបាយ និងបច្ចេកទេសសំខាន់ៗរបស់អាស៊ាន ដែលកំពុងប្រឹងប្រែងជំរុញកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន ដើម្បីពង្រឹងការតាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងតំបន់ អនុវត្តផែនទីមគ្គុទ្ទេសន៍នៃសមាហរណកម្មរូបិយវត្ថុ-ហិរញ្ញវត្ថុអាស៊ាន និងអនុវត្តយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ាន ។

**មជ្ឈមណ្ឌល SEACEN** ប្រតិភូធនាគារជាតិនៃកម្ពុជាបានចូលរួមសន្និសីទថ្នាក់ទេសាភិបាលធនាគារកណ្តាលលើកទី៤៤ ស្តីពី ការអភិរក្សរូបិយវត្ថុនិងស្ថិរភាពហិរញ្ញវត្ថុ និងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល SEACEN លើកទី២៨ នៅទីក្រុងកូឡាឡំពួរ ប្រទេសម៉ាឡេស៊ី និងចូលរួមកិច្ចប្រជុំគណៈកម្មការប្រតិបត្តិ SEACEN លើកទី៧ (EXCO) នៅខេត្តយុគយ៉ាកាតា ប្រទេសឥណ្ឌូណេស៊ី ។ ធនាគារជាតិនៃកម្ពុជា ក៏បានបញ្ជូនមន្ត្រីជំនាញទៅចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានានៅក្នុង និងក្រៅប្រទេស ដែលរៀបចំឡើងដោយមជ្ឈមណ្ឌល SEACEN ផងដែរ ដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នា ។

**កិច្ចសហប្រតិបត្តិការទ្វេភាគី** ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលបារាំង ធនាគារកណ្តាលថៃ ធនាគារកណ្តាលវៀតណាម ធនាគារកណ្តាលឡាវ ធនាគារកណ្តាលម៉ាឡេស៊ី ធនាគារកណ្តាលកូរ៉េ ធនាគារកណ្តាលលុចហ្សំបួរ ធនាគារកណ្តាលអាល្លឺម៉ង់ និងធនាគារកណ្តាលនៃបណ្តាប្រទេសអាស៊ានមួយចំនួនទៀត ។ នៅចុងឆ្នាំ២០០៩ កន្លងមក ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយធនាគារកណ្តាលស្រីលង្កា និងធនាគារកណ្តាលនេប៉ាល់ ដើម្បីពង្រីកសហប្រតិបត្តិការ និងផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ក្នុងការគ្រប់គ្រងធនាគារកណ្តាល និងការបណ្តុះបណ្តាលមន្ត្រីជំនាញរបស់យើង ។

សរុបមក សមិទ្ធផលទាំងឡាយដែលយើងមានសព្វថ្ងៃនេះ គឺកើតចេញពីការខិតខំប្រឹងប្រែងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងការប្រើប្រាស់កម្លាំងសរុបរបស់មន្ត្រីបុគ្គលិកយើងទាំងអស់គ្នា ។ ដើម្បីជ្រាបពីសមិទ្ធផលលំអិតផ្សេងទៀត សូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំរបស់យើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។

ដើម្បីអបអរសាទរ ចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ដែលបានបម្រើការងាររយៈពេល ៣០ឆ្នាំ និងដើម្បីអបអរសាទរសមិទ្ធផលការងារ ដែលមន្ត្រីបុគ្គលិករបស់យើងបានរួមចំណែកកសាងកន្លងមកនេះ ធនាគារជាតិនៃកម្ពុជាបានសម្រេចផ្តល់សញ្ញាមាសអនុស្សាវរីយ៍ធនាគារជាតិនៃកម្ពុជា ជូនមន្ត្រីបុគ្គលិក : *ទី១)* -មន្ត្រីបុគ្គលិកដែលបានបម្រើការងាររយៈពេល ៣០ឆ្នាំ សរុប ៤៩ នាក់ *ទី២)* -មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាដែលមានស្នាដៃល្អបានទទួលមេដាយពីរាជរដ្ឋាភិបាលចំនួន ១៣១នាក់ ទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខាខេត្ត ហើយយើងនឹងបន្តធ្វើពិធីបែបនេះនៅឆ្នាំក្រោយទៀតជាបន្តបន្ទាប់ ។

ទន្ទឹមពេលនេះដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការ និងការខិតខំប្រឹងប្រែងរបស់សមាជិកក្រុមប្រឹក្សាភិបាលនិងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានរួមចំណែកកសាងធនាគារជាតិនៃកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរគួរជាទីមោទនៈ ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះតទៀត ។ អង្គសន្និបាតរបស់យើងនឹងប្រព្រឹត្តទៅរយៈពេលពីរថ្ងៃ សូម លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ខិតខំស្តាប់របាយការណ៍ស្តីពីលទ្ធផលការងារដែលបានអនុវត្តកន្លងមក និងអនុសាសន៍ផ្សេងៗ ដើម្បីយកទៅអនុវត្តការងាររបស់ខ្លួនឱ្យបានជោគជ័យ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនេះ សូមឱ្យអង្គសន្និបាតរបស់យើងថ្ងៃនេះមានដំណើរការប្រកបដោយជោគជ័យ ។

ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**!